**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
លេខ : ......២២ ដស. សាលា..........

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៨ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/១០៤៥ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការដំឡើងឋានៈ និងតែងតាំងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៩/០២២ ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការដំឡើងឋានៈជារដ្ឋលេខាធិការ និងតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៩/០៤៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៩/១២៣៥ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២០/៦១១ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការតែងតាំងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២០/៩៦៨ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១២៨៥ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការតែងតាំងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២១/៣០៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ស្តីពីការតែងតាំងរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងទីប្រឹក្សា នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២១/៣០៦ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ស្តីពីការផ្ទេរនិងតែងតាំងរដ្ឋលេខាធិការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបែងចែកការកិច្ចជូនថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដូចខាងក្រោម៖

១. ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទទួលបន្ទុកដឹកនាំការងាររួម។

២. ឯកឧត្តម **ខាយ ឃុនហេង** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងាររដ្ឋបាលទូទៅ ស្ថិតិ សរុប និងការងារពាក់ព័ន្ធនឹងក្រសួងផែនការ
- ការងារប្រយុទ្ធនឹងជំងឺអេដស៍ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ការងារជនមានពិការភាព
- ការងារសម្ព័ន្ធមេត្រីភាពជាមួយកងពលតូចថ្មើរជើងលេខ៤១។

៣. ឯកឧត្តម **ឯក វណ្ណឌី** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងារនាយកដ្ឋានគ្រប់គ្រងនិងនិយ័តកម្មប្រៃសណីយ៍ឯកជន និងនាយកដ្ឋានគ្រប់គ្រងសេវាប្រៃសណីយ៍ហិរញ្ញវត្ថុនិងភស្តុភាកម្ម នៃអគ្គនាយកដ្ឋានប្រៃសណីយ៍
- ការងារសហប្រតិបត្តិការជាមួយសហភាពប្រៃសណីយ៍សកល (UPU)
- ការងារគ្រប់គ្រងគ្រោះមហន្តរាយ និងការងារដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា។

៤. លោកជំទាវ **រស់ សុវត្ថា** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងារនាយកដ្ឋានគោលនយោបាយផ្កាយរណប នៃអគ្គនាយកដ្ឋានទូរគមនាគមន៍
- ការងារគោលនយោបាយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម
- ការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ការងារលើកកម្ពស់សីលធម៌សង្គមនិងតម្លៃស្ត្រីខ្មែរ។

៥. ឯកឧត្តម **ភាន ច័ន្ទមេត្តា** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងារស្រាវជ្រាវ និងរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យប្រៃសណីយ៍ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារពិនិត្យ និងផ្តល់យោបល់លើឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងក្រសួង
- ការងារនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល។

៦. លោកជំទាវ **ប្រាក់ ច័ន្ទណាយ** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងារនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍ នៃអគ្គនាយកដ្ឋានប្រៃសណីយ៍
- ការងារប្រៃសណីយ៍កម្ពុជា
- ការងារសហប្រតិបត្តិការជាមួយសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក (APPU)
- ការងារយេនឌ័រ និងការទប់ស្កាត់អំពើហិង្សាលើកុមារ
- ការងារសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងការអភិវឌ្ឍ
- ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ការងារគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

៧. ឯកឧត្តម **សុខ ពុទ្ធិវុធ** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងារនាយកដ្ឋានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធព័ត៌មានជាតិនិងគ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាល នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារគោលនយោបាយរដ្ឋាភិបាលឌីជីថល
- ការងារសេវាឌីជីថលសាធារណៈ
- ការងារសហប្រតិបត្តិការអន្តរជាតិទ្វេភាគីនិងពហុភាគី លើកលែងការងារក្នុងចង្កោមរបស់ **ឯកឧត្តមនិងលោកជំទាវ** រដ្ឋលេខាធិការ
- ការងារគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់ស៍វិទ្យុ ជាមួយ ឯកឧត្តម **ខូច មករា**
- ការងារសហប្រតិបត្តិការជាមួយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិ ជាមួយ ឯកឧត្តម **ខូច មករា**។

៨. ឯកឧត្តម **ជា មានិត** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងារទូរគមនាគមន៍កម្ពុជា
- ការងារអាសយដ្ឋានអេឡិចត្រូនិក (IP Address) និងការងារគ្រប់គ្រងឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

៩. ឯកឧត្តម **ខូច មករា** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួល៖
- ការងាររៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន លើកលែងការងារក្នុងចង្កោមរបស់ **ឯកឧត្តមនិងលោកជំទាវ** រដ្ឋលេខាធិការ
- ការងារបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា
- ការងារបច្ចេកទេសនៃមូលនិធិកាតព្វកិច្ចសេវាសកល (USO) និងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (CBRD)
- ការងារស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល
- ការងារទីក្រុងឆ្លាត (Smart City)
- ការងាររួមរបស់ក្រុមការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

- ការងារគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់វិទ្យុ ជាមួយ ឯកឧត្តម **សុខ ពុទ្ធិវុធ**
- ការងារសហប្រតិបត្តិការជាមួយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិ ជាមួយ ឯកឧត្តម **សុខ ពុទ្ធិវុធ**។

១០. ឯកឧត្តម **ជាប សន្តារតន៍** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងារនិយ័តករទូរគមនាគមន៍កម្ពុជា
- ការងារអគ្គាធិការដ្ឋាន
- ការងារហិរញ្ញវត្ថុ និងបុគ្គលិក
- ការងារកែទម្រង់រដ្ឋបាលសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការងាររដ្ឋបាលនិងហិរញ្ញវត្ថុនៃមូលនិធិកាតព្វកិច្ចសេវាសកល (USO) និងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (CBRD)។

១១. ឯកឧត្តម **ម៉ូច ចរិយា** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងារនាយកដ្ឋានគោលនយោបាយទូរគមនាគមន៍ នៃអគ្គនាយកដ្ឋានទូរគមនាគមន៍
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារគោលនយោបាយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម ជាមួយ លោកជំទាវ **រស់ សុរក្សា**។

១២. ឯកឧត្តម **ជុន វ៉ាត** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងារនាយកដ្ឋានគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានសម្រាប់ជនបទ នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារបណ្ណាល័យឌីជីថល (Digital Library)
- ការងារសូចនាករក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារស្តង់ដារទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងការងារហត្ថលេខាឌីជីថល (Digital Signature) ជាមួយ ឯកឧត្តម **ខូច មករា**។

១៣. ឯកឧត្តម **ឃិនឡៅ ពុទ្ធិរ៉ា** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងារបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកសន្តិសុខឌីជីថល
- ការងារឧក្រិដ្ឋកម្មសាយប័រ (Cybercrime)
- ការងារសន្តិសុខសាយប័រ (Cybersecurity) និងការងារទិន្នន័យឯកជនភាព (Personal Data Privacy) ជាមួយ ឯកឧត្តម **ខូច មករា**
- ការងារអគ្គាធិការដ្ឋាន ជាមួយ ឯកឧត្តម **ជាប សន្តារតន៍**។

១៤. ឯកឧត្តម **សង់ ស៊ីណាវ៉ុង** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ និងសេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យឯកជនភាព
- ការងាររៀបចំសទ្ទានុក្រមបច្ចេកសព្ទបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារសហប្រតិបត្តិការអន្តរជាតិ ជាមួយ ឯកឧត្តម **សុខ ពុទ្ធិវុធ**
- ចង្កោមការងាររបស់ ឯកឧត្តម **ខូច មករា**។

១៥. ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ការងារពាក់ព័ន្ធនឹងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- ការងារលេខកូដប្រៃសណីយ៍
- ការងារបណ្តុះបណ្តាលមន្ត្រីរាជការ
- ការងារក្នុងវិស័យប្រៃសណីយ៍ជាមួយ ឯកឧត្តម **ឯក វណ្ណឌី** និងលោកជំទាវ **ប្រាក់ ច័ន្ទណាយ**
- ការងារស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ជាមួយ ឯកឧត្តម **ខូវ មករា**។

១៦. ឯកឧត្តម **សូ ទិសុទ្ធី** រដ្ឋលេខាធិការ ទទួលបន្ទុកជួយសម្របសម្រួលៈ
- ការងារនាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារទំនាក់ទំនងសាធារណៈ និងជាអ្នកនាំពាក្យរបស់ក្រសួង
- ការងារជំរុញធុរកិច្ចប្រៃសណីយ៍
- ការងារជំរុញការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ចថ្មីឌីជីថល ជាមួយ ឯកឧត្តម **ខូវ មករា**
- ការងារសួចនាករក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាមួយ ឯកឧត្តម **ជុន វ៉ាត**។

១៧. ឯកឧត្តម **ភុយ ពុំ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលការងាររបស់ឯកឧត្តម **ជាប សត្ថារតន៍** លើការងារហិរញ្ញវត្ថុ និងការងារបៀវត្សមន្ត្រីរាជការ។

១៨. ឯកឧត្តម **មាស ប៉ូ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ
- ឯកឧត្តម **ខាយ ឃុនហេង** លើការងារបូកសរុបរបាយការណ៍ និងកម្មវិធីវិនិយោគសាធារណៈ (PIP)
- ឯកឧត្តម **ជា មានិត** លើការងារទំនាក់ទំនងជាមួយស្ថាប័ន ICANN
- ឯកឧត្តម **សត់ ស៊ីណាឌ៉ុង** លើការងារសហប្រតិបត្តិការអន្តរជាតិ និងការងាររៀបចំសទ្ទានុក្រមបច្ចេកសព្ទបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- អ្នកនាំពាក្យរបស់ក្រសួង
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

១៩. ឯកឧត្តម **អេ សុភា** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ
- ឯកឧត្តម **ខាយ ឃុនហេង** លើការងារស្ថិតិ ការងារប្រយុទ្ធនឹងជំងឺអេដស៍និងប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ឯកឧត្តម **ជាប សត្ថារតន៍** លើការងារកែទម្រង់រដ្ឋបាលសាធារណៈ និងការងារបុគ្គលិក
- ឯកឧត្តម **ម៉ម អំណាត់** លើការងារបណ្តុះបណ្តាលមន្ត្រីរាជការ
- ការងារគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

២០. ឯកឧត្តម **សាន់ សារី** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ
- ឯកឧត្តម **ខាយ ឃុនហេង** លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការងារជនមានពិការភាព
- ឯកឧត្តម **ឯក វណ្ណឌី** លើការងារគ្រប់គ្រងគ្រោះមហន្តរាយ
- ឯកឧត្តម **សុខ ពុទ្ធិវុធ** លើការងារសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសកាន់សាសនាឥស្លាម
- ការងារបរិស្ថាននិងសុខភាព។

២១. ឯកឧត្តម **លី ណារិទ្ធិ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ
- ឯកឧត្តម **សុខ ពុទ្ធិវុធ** លើការងារសហប្រតិបត្តិការជាមួយសហភាពទូរគមនាគមន៍អន្តរជាតិ (ITU) និងសហគមន៍ទូរគមនាគមន៍អាស៊ី-ប៉ាស៊ីហ្វិក (APT)
- ឯកឧត្តម **ជាប សត្ថារតន៍** លើការងាររបស់និយ័តករទូរគមនាគមន៍កម្ពុជា
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

២២. លោកជំទាវ **តឹក អមរា** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួល៖
- ឯកឧត្តម **ខុច មករា** លើការងាររួមរបស់ក្រុមការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ឯកឧត្តម **ជាប សន្តារតន៍** លើការងារលិខិតបទដ្ឋានគតិយុត្តរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- ឯកឧត្តម **ជុន វ៉ាត** លើការងារសូចនាករក្នុងវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

២៣. ឯកឧត្តម **ទេព ច័ន្ថា** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលការងាររបស់ឯកឧត្តម **ជាប សន្តារតន៍** លើការងារហិរញ្ញវត្ថុ។

២៤. លោកជំទាវ **លីម លឿន** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលលោកជំទាវ **ប្រាក់ ច័ន្ទណាយ** លើការងារនាយកដ្ឋានគោលនយោបាយប្រៃសណីយ៍ នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ ការងារគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការងារសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងការអភិវឌ្ឍ។

២៥. លោកជំទាវ **ទេព វ៉ូដា** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួល៖
- ឯកឧត្តម **ខាយ ឃុនហេង** លើការងារពាក់ព័ន្ធនឹងក្រសួងផែនការ ការងារប្រយុទ្ធនឹងជំងឺអេដស៍និងប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការងារជនមានពិការភាព
- លោកជំទាវ **រស់ សុវត្ថា** លើការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងការងារលើកកម្ពស់សីលធម៌សង្គមនិងតម្លៃស្ត្រីខ្មែរ
- លោកជំទាវ **ប្រាក់ ច័ន្ទណាយ** លើការងារគោលនយោបាយប្រៃសណីយ៍ ការងារប្រៃសណីយ៍កម្ពុជា និងការងារយេនឌ័រនិងការទប់ស្កាត់អំពើហិង្សាលើកុមារ
- ឯកឧត្តម **ជុន វ៉ាត** លើការងារសូចនាករក្នុងវិស័យប្រៃសណីយ៍។

២៦. លោកជំទាវ **ម៉ី ធឿន** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួល៖
- លោកជំទាវ **រស់ សុវត្ថា** លើការងាររបស់នាយកដ្ឋានគោលនយោបាយផ្កាយរណប នៃអគ្គនាយកដ្ឋានទូរគមនាគមន៍ និងការងារគោលនយោបាយប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម
- ឯកឧត្តម **សុខ ពុទ្ធិវុធ** លើការងារសហប្រតិបត្តិការទ្វេភាគីជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម
- ឯកឧត្តម **ជុន វ៉ាត** លើការងារសូចនាករក្នុងវិស័យទូរគមនាគមន៍
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

២៧. ឯកឧត្តម **ឈី សុខា** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួល៖
- ឯកឧត្តម **ម៉ូវ ចរិយា** លើការងារគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍
- ឯកឧត្តម **ជុន វ៉ាត** លើការងារសូចនាករក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

២៨. ឯកឧត្តម **ហួត ចាន់យ៉ារ៉េត** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួល ៖
- ឯកឧត្តម **ខាយ ឃុនហេង** លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ឯកឧត្តម **ឯក វណ្ណឌី** លើការងាររបស់នាយកដ្ឋានគ្រប់គ្រងនិងនិយ័តកម្មប្រៃសណីយ៍ឯកជន នាយកដ្ឋានគ្រប់គ្រងសេវាប្រៃសណីយ៍ហិរញ្ញវត្ថុនិងភស្តុភារកម្ម នៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងការងារគ្រប់គ្រងគ្រោះមហន្តរាយ
- ឯកឧត្តម **ម៉ម អំណាត់** លើការងារលេខកូដប្រៃសណីយ៍
- ការងារក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

២៩. ឯកឧត្តម **លីវ សុផាណារិទ្ធិ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **ជា មានិត** លើការងាររបស់ទូរគមនាគមន៍កម្ពុជា ជាមួយឯកឧត្តម **ញ៉ឹក កោសល្យវិទ្យា** ការងារអាសយដ្ឋានអេឡិចត្រូនិក (IP Address) និងការងារគ្រប់គ្រងឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត
- ឯកឧត្តម **ខូវ មករា** លើការងារមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានទូរគមនាគមន៍ និងការងារបច្ចេកទេសមូលនិធិកាតព្វកិច្ចសេវាសកល (USO)
- ឯកឧត្តម **ឃិនឡៀង ពុទ្ធិរ៉ា** លើការងារបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកសន្តិសុខឌីជីថល ការងារឧក្រិដ្ឋកម្មសាយប័រ (Cybercrime) ការងារសន្តិសុខសាយប័រ (Cybersecurity) និងការងារទិន្នន័យឯកជនភាព
- អ្នកនាំពាក្យរបស់ក្រសួង។

៣០. ឯកឧត្តម **សារុន វ៉ាឌី** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលការងារៈ

- ឯកឧត្តម **ខាយ ឃុនហេង** លើការងារសម្ព័ន្ធមេត្រីភាពជាមួយកងពលតូចថ្មើរជើងលេខ៤១
- ឯកឧត្តម **ជាប សន្តារតន៍** លើការងារហិរញ្ញវត្ថុ និងការងាររដ្ឋបាលនិងហិរញ្ញវត្ថុមូលនិធិកាតព្វកិច្ចសេវាសកល (USO)។

៣១.ឯកឧត្តម **លីវ គឹមហេង** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលការងារៈ

- ឯកឧត្តម **ខាយ ឃុនហេង** លើការងាររដ្ឋបាលទូទៅ
- ឯកឧត្តម **ជាប សន្តារតន៍** លើការងាររដ្ឋបាលនិងហិរញ្ញវត្ថុមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (CBRD)
- ឯកឧត្តម **ម៉ម អំណាត់** លើការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

៣២.ឯកឧត្តម **គង់ ផល្លៈ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **ជាប សន្តារតន៍** លើការងារកែទម្រង់របស់ក្រសួង
- ឯកឧត្តម **ម៉ម អំណាត់** លើការងារពាក់ព័ន្ធនឹងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ការងារនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល
- ការងារស្រាវជ្រាវ និងរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារពិនិត្យ និងផ្តល់យោបល់លើឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួង។

៣៣.ឯកឧត្តម **ប៉ា ចន្ទវិចិត្រ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **ឯក វណ្ណឌី** លើការងារសហប្រតិបត្តិការជាមួយសហភាពប្រៃសណីយ៍សកល (UPU)
- លោកជំទាវ **ប្រាក់ ច័ន្ទណាយ** លើការងារប្រៃសណីយ៍កម្ពុជា និងការងារសហប្រតិបត្តិការជាមួយសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក (APPU)
- ឯកឧត្តម **ខូវ មករា** លើការងារទីក្រុងវៃឆ្លាត (Smart City)
- ឯកឧត្តម **ជុន វ៉ាត** លើការងារសូចនាករក្នុងវិស័យប្រៃសណីយ៍
- ឯកឧត្តម **ម៉ម អំណាត់** លើការងារលេខកូដប្រៃសណីយ៍
- ឯកឧត្តម **សូ វិសុទ្ធី** លើការងារជំរុញធុរកិច្ចប្រៃសណីយ៍និងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ចថ្មីឌីជីថល និងការងារនាយកដ្ឋានឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

៣៤. ឯកឧត្តម **ញឹក កោសល្យវិចិត្រ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **ជា មានិត** លើការងារទូរគមនាគមន៍កម្ពុជា ជាមួយ ឯកឧត្តម **លីវ សុផាណារិទ្ធិ**
- ឯកឧត្តម **ខូវ មករា** លើការងារហេដ្ឋារចនាសម្ព័ន្ធនិងសេវាទូរគមនាគមន៍
- ឯកឧត្តម **ជាប សត្ថារតន៍** លើការងារអគ្គាធិការដ្ឋាន
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

៣៥. ឯកឧត្តម **លឹម ឧុទ្ធី** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **ខូវ មករា** លើការងារគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់សិវិទ្យុ
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

៣៦. ឯកឧត្តម **ស៊ា ណារ៉េត** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- លោកជំទាវ **រស់ សូរត្នា** លើការងារគោលនយោបាយផ្កាយរណប
- ឯកឧត្តម **ខូវ មករា** លើការងារគ្រប់គ្រងធនធានវិសាលគមន៍ហ្វ្រេកង់សិវិទ្យុ
- ការងារលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។

៣៧. ឯកឧត្តម **ទូច យ៉ាវ៉ាន់ឌី** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **សុខ ពុទ្ធិវុធ** លើការងារសេវាឌីជីថលសាធារណៈ
- ឯកឧត្តម **ខូវ មករា** លើការងារបច្ចេកទេសមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (CBRD)
- ឯកឧត្តម **ជុន វ៉ាត** លើការងារសូចនាករក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារធ្វើតេស្តសាកល្បងប្រព័ន្ធបច្ចេកវិទ្យាឌីជីថល
- ការងារជំរុញឌីជីថលូបនីយកម្មក្រសួង។

៣៨. ឯកឧត្តម **កង ច័ន្ទតារារ័ត្ន** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **សុខ ពុទ្ធិវុធ** លើការងារគោលនយោបាយរដ្ឋាភិបាលឌីជីថល
- ឯកឧត្តម **ខូវ មករា** លើការងារសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា
- ឯកឧត្តម **ជាប សត្ថារតន៍** លើការងារកែទម្រង់របស់ក្រសួង
- ឯកឧត្តម **ម៉ម អំណាត់** លើការងារបណ្តុះបណ្តាលមន្ត្រីរាជការ
- ឯកឧត្តម **សូ វិសុទ្ធី** លើការងារជំរុញធុរកិច្ចប្រៃសណីយ៍និងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ចថ្មីឌីជីថល។

៣៩. ឯកឧត្តម **កែវ សុទ្ធិ** អនុរដ្ឋលេខាធិការ ជួយសម្របសម្រួលៈ

- ឯកឧត្តម **ខូវ មករា** លើការងារអភិបាលកិច្ចឌីជីថលនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា
- ឯកឧត្តម **ជាប សត្ថារតន៍** លើការងារកែទម្រង់របស់ក្រសួង
- ឯកឧត្តម **សង់ ស៊ីណាវ៉ុង** លើការងារសហប្រតិបត្តិការអន្តរជាតិ
- ឯកឧត្តម **ម៉ម អំណាត់** លើការងារបណ្តុះបណ្តាលមន្ត្រីរាជការ
- ឯកឧត្តម **សូ វិសុទ្ធី** លើការងារជំរុញធុរកិច្ចប្រៃសណីយ៍និងការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ចថ្មីឌីជីថល និងការងារសូចនាករក្នុងវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

- ការងារស្រាវជ្រាវ និងរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការងារនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានរដ្ឋបាល
- ការងារពិនិត្យ និងផ្តល់យោបល់លើឯកសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួង។

**ប្រការ២ .-**

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៣ .-**

ការបែងចែកភារកិច្ចនៅក្នុងប្រការ១ខាងលើ អាចធ្វើការកែសម្រួលបាន ក្នុងករណីចាំបាច់។

**ប្រការ៤ .-**

សេចក្តីសម្រេចលេខ០១៤ បទ.សសរ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍គ្រប់ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១រោច ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ